# សេចក្តីប្រកាសព័ត៌មានរួមៈ កម្ពុជា និងសហភាពអឺរ៉ុប
# រៀបចំកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី១១

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២

កិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១១ ត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ ក្នុងទម្រង់ដោយផ្ទាល់ផង និងតាមរយៈប្រព័ន្ធវីដេអូផង នៅថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០២២ បន្ទាប់ពីបានបញ្ចប់កិច្ចប្រជុំអនុក្រុមចំនួន០៣ រួមមានៈ (១) ពាណិជ្ជកម្ម និងការវិនិយោគ (២) កិច្ចសហប្រតិបត្តិការ និង (៣) ការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ និងយុត្តិធម៌ អភិបាលកិច្ច និងសិទ្ធិមនុស្ស រួចមក។ កិច្ចប្រជុំអនុក្រុមនីមួយៗបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៥ ដល់ ២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ហើយត្រូវបានពន្យារពេលចាប់តាំងពីពេលនោះមក ដោយសារតែការរំខានបណ្តាលមកពីជំងឺកូវីដ-១៩។ កិច្ចប្រជុំគណៈកម្មាធិការចម្រុះនេះ ដឹកនាំដោយ **ឯកឧត្តម លុយ ដាវីត** រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និង**លោកស្រី** Paola PAMPALONI អនុប្រធានគ្រប់គ្រងប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិកនៃមន្ទីរកិច្ចការបរទេសសហភាពអឺរ៉ុប។

កិច្ចប្រជុំបានពិនិត្យលើវឌ្ឍនភាពសម្រេចបាន គិតចាប់តាំងពីកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១០ ដែលបានប្រព្រឹត្តទៅនៅទីក្រុងប្រ៊ុចសែល ក្នុងឆ្នាំ២០១៨ ព្រមទាំងបានផ្លាស់ប្តូរទស្សនៈលើប្រធានបទជាច្រើនពាក់ព័ន្ធនឹងបញ្ហាទ្វេភាគី និងពហុភាគី ក្នុងនោះរួមទាំងការវិវត្តនយោបាយថ្មីៗទាំងនៅកម្ពុជា និងសហភាពអឺរ៉ុប ផងដែរ។ កិច្ចប្រជុំក៏បានពិភាក្សាផងដែរពីស្ថានភាពនៅប្រទេសអ៊ុយក្រែន ស្ថានភាពសេដ្ឋកិច្ចសកល ការប្រែប្រួលអាកាសធាតុ ព្រមទាំងការធ្វើជាប្រធានអាស៊ានរបស់កម្ពុជា ស្ថានភាពនៅប្រទេសមីយ៉ាន់ម៉ា ភាពជាដៃគូយុទ្ធសាស្ត្រ និងកិច្ចសហប្រតិបត្តិការសហភាពអឺរ៉ុប-អាស៊ាន នៅក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិក។

សហភាពអឺរ៉ុបក៏បានកោតសរសើរកម្ពុជាផងដែរ ចំពោះជោគជ័យនៃការរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ (ASEM13) កាលពីឆ្នាំ២០២១ កន្លងទៅ ដែលបានបង្ហាញពីកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរួមគ្នា ក្នុងការដោះស្រាយជំងឺរាតត្បាតកូវីដ-១៩ ក៏ដូចជាក្នុងការធានាឱ្យបានថាពហុភាគីនិយមនៅតែបន្តមានភាពពាក់ព័ន្ធ និងមានប្រសិទ្ធភាពដោះស្រាយបញ្ហាតំបន់ និងសកល។ បន្ថែមលើសពីនេះ សហភាពអឺរ៉ុបបានសម្តែងការគាំទ្រយ៉ាងពេញទំហឹងចំពោះការធ្វើជាប្រធានអាស៊ានរបស់កម្ពុជានៅឆ្នាំ២០២២ ក៏ដូចជាការតែងតាំង **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ធ្វើជាប្រេសិតពិសេសរបស់អាស៊ាន

សម្រាប់ប្រទេសមីយ៉ាន់ម៉ាផងដែរ។ សហភាពអឺរ៉ុបបានគូសបញ្ជាក់បន្ថែមថាការតែងតាំង **ឯកឧត្តម Igor Driesmans** ជាប្រេសិតពិសេសរបស់ EU សម្រាប់ប្រទេសមីយ៉ាន់ម៉ា សបញ្ជាក់ឱ្យឃើញពីការគាំទ្រយ៉ាងខ្លាំងក្លារបស់សហភាពអឺរ៉ុបចំពោះអាស៊ាន និងប្រេសិតពិសេសរបស់អង្គការសហប្រជាជាតិក្នុងការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុចរបស់អាស៊ាន។

កិច្ចប្រជុំអនុក្រុមស្តីពីការកសាងស្ថាប័ន កំណែទម្រង់រដ្ឋបាល កំណែទម្រង់ច្បាប់ និងយុត្តិធម៌ អភិបាលកិច្ច និងសិទ្ធិមនុស្ស បានពិភាក្សា និងផ្លាស់ប្តូរទស្សនៈលើការអភិវឌ្ឍសំខាន់ៗស្តីពីសិទ្ធិមនុស្ស (រួមទាំងសិទ្ធិស៊ីវិល និងនយោបាយ ការងារ ដីធ្លី និងសិទ្ធិស្ត្រី ផងដែរ) គោលនយោបាយប្រឆាំងការជួញដូរមនុស្ស និងការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងកំណែទម្រង់ពហុទិដ្ឋភាព និងការត្រៀមខ្លួនរបស់កម្ពុជាឆ្ពោះទៅការរៀបចំបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២ នាពេលខាងមុខនេះ។ សហភាពអឺរ៉ុបបានគូសបញ្ជាក់អំពីសារសំខាន់យ៉ាងខ្លាំងនៃការប្រកាន់ខ្ជាប់នូវលទ្ធិប្រជាធិបតេយ្យពហុនិយម សិទ្ធិមនុស្ស សេរីភាពជាមូលដ្ឋាន សិទ្ធិការងារ និងនីតិរដ្ឋ។ សហភាពអឺរ៉ុបបានកត់សម្គាល់ពីកិច្ចសហប្រតិបត្តិការ និងការចូលរួមរបស់កម្ពុជាជាមួយនឹងយន្តការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក៏ដូចជាការប្តេជ្ញាចិត្ត និងកាតព្វកិច្ចដែលកម្ពុជាបានទទួលយក ស្ថិតក្រោមច្បាប់ និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស។ ភាគីទាំងពីរបានកត់សម្គាល់ពីសារសំខាន់នៃការគាំទ្ររបស់សហភាពអឺរ៉ុបលើការកសាងសមត្ថភាព និងជំនួយហិរញ្ញវត្ថុនៅក្នុងវិស័យកិច្ចសហប្រតិបត្តិការនេះ ក៏ដូចជានៅក្នុងទិដ្ឋភាពនីតិរដ្ឋ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។

កិច្ចប្រជុំអនុក្រុមស្តីពីពាណិជ្ជកម្ម និងការវិនិយោគ បានពិនិត្យមើលឡើងវិញទៅលើពាណិជ្ជកម្មទ្វេភាគីកម្ពុជា-សហភាពអឺរ៉ុប និងបរិយាកាសវិនិយោគនៅកម្ពុជា។ ក្នុងឆ្នាំ២០២០ និង២០២១ ពាណិជ្ជកម្មទ្វេភាគីរវាងភាគីទាំងពីរមានតម្លៃ ៤,៣ ពាន់លានអឺរ៉ូ[1] និង ៤,៥ ពាន់លានអឺរ៉ូ ក្នុងឆ្នាំនីមួយៗ។ កិច្ចប្រជុំក៏បានពិភាក្សាផងដែរអំពីវិធានការស្តារសេដ្ឋកិច្ចឡើងវិញ ទំនាក់ទំនងពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី រួមទាំងការដកជាបណ្តោះអាសន្ននូវផ្នែកខ្លះនៃការអនុគ្រោះពន្ធពាណិជ្ជកម្មរបស់សហភាពអឺរ៉ុបក្រោមគម្រោងគ្រប់យ៉ាងលើកលែងតែសព្វាវុធ (EBA) កិច្ចសហប្រតិបត្តិការបច្ចេកទេស បញ្ហានៃការចូលទៅកាន់ទីផ្សារ ព្រមទាំងកិច្ចខិតខំប្រឹងប្រែងជាបន្តដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងថែមទៀតនូវបរិយាកាសធុរកិច្ច រួមទាំងច្បាប់វិនិយោគថ្មី និងការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា។ ភាគីទាំងពីរក៏បាន ប្តេជ្ញាពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដើម្បីធានាថាបរិយាកាសវិនិយោគរបស់កម្ពុជានៅតែបើកចំហ មានការសម្របសម្រួលយ៉ាងល្អ មានលក្ខណៈប្រកួតប្រជែង និងអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព។ កិច្ចប្រជុំក៏បានផ្លាស់ប្តូរទស្សនៈអំពីការអភិវឌ្ឍពាណិជ្ជកម្មតំបន់ និងសកល ដែលក្នុងនោះរួមបញ្ចូលទាំងបច្ចុប្បន្នភាពស្តីពីសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងអាស៊ាន និងនៅទូទាំងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ទំនាក់ទំនងពាណិជ្ជកម្មតំបន់អាស៊ាន-សហភាពអឺរ៉ុប ព្រមទាំងបច្ចុប្បន្នភាពស្តីពីកំណែទម្រង់អង្គការពាណិជ្ជកម្មពិភពលោក ជាដើម។

---

[1] Eurostat Comext: [https://webgate.ec.europa.eu/isdb_results/factsheets/country/details_cambodia_en.pdf](https://webgate.ec.europa.eu/isdb_results/factsheets/country/details_cambodia_en.pdf)

ក្នុងអំឡុងពេលកិច្ចប្រជុំអនុក្រុមស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ភាគីទាំងពីរបានកត់សម្គាល់អំពីវឌ្ឍនភាពសម្រេចបានពាក់ព័ន្ធនឹងការបន្តគាំទ្ររបស់សហភាពអឺរ៉ុបដល់ការអភិវឌ្ឍរបស់កម្ពុជា។ ក្នុងន័យនេះ អង្គប្រជុំបានវាយតម្លៃខ្ពស់ចំពោះការអនុម័តកម្មវិធីសូចនាករពហុឆ្នាំនៃកិច្ចសហប្រតិបត្តិការរបស់សហភាពអឺរ៉ុប (២០២១-២០២៧) ថ្មី ដែលមានតម្លៃ ១៥៥ លានអឺរ៉ូ សម្រាប់រយៈពេល៣ឆ្នាំ គិតចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ ដោយផ្តោតលើវិស័យអាទិភាពចំនួនបីគឺៈ "កំណើនបៃតង និងការងារសមរម្យ" "ការអប់រំ និងការអភិវឌ្ឍជំនាញ" និង "អភិបាលកិច្ចល្អ" ស្របតាមរបៀបវារៈឆ្នាំ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងជាមួយនឹងការពង្រឹងការចូលរួមរបស់ក្រុមអឺរ៉ុប (Team Europe) ក្រោមគំនិតផ្តួចផ្តើមរួមរបស់អឺរ៉ុប។ លើសពីនេះ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈទៅលើវឌ្ឍនភាពកំណែទម្រង់គោលនយោបាយ ជាពិសេសលើវិស័យទាំងឡាយណាដែលទទួលបានការគាំទ្រពីសហភាពអឺរ៉ុប ដូចជា ការអប់រំ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការការពារសង្គម និងជលផលជាដើម។ ជាមួយគ្នានេះ ភាគីទាំងពីរ បានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពក្នុងកម្មវិធីកិច្ចសហប្រតិបត្តិការតាមប្រធានបទ និងតំបន់ ក្នុងនោះរួមទាំងការគាំទ្រសមាហរណកម្មតំបន់អាស៊ានពីសហភាពអឺរ៉ុប (ARISE Plus) ផងដែរ។ សហភាពអឺរ៉ុបបានអបអរសាទរកម្ពុជាចំពោះការអនុម័តយុទ្ធសាស្ត្ររយៈពេលវែងសម្រាប់អព្យាក្រឹត្យភាពកាបូន និងបានសម្តែងនូវការប្តេជ្ញាចិត្តលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីលើសកម្មភាពអាកាសធាតុ។

កិច្ចប្រជុំបានបញ្ចប់ទៅប្រកបដោយបរិយាកាសស្ថាបនា និងស្និទ្ធស្នាល ព្រមទាំងបានឯកភាពថាកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុប លើកទី១២ និងកិច្ចប្រជុំអនុក្រុមចំនួនបីទៀតនឹងត្រូវរៀបចំឡើងនៅក្នុងឆ្នាំ២០២៣ នៅទីក្រុងប្រ៊ុចសែល។